ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ
និង ដឹកជញ្ជូន

លេខ : 012 សក.សជណ

រាជធានីភ្នំពេញ.ថ្ងៃទី 11 ខែ 03 ឆ្នាំ 2002

# សេចក្តីជូនដំណឹង

**យោង** :
- លិខិតលេខ ៣០២ សជណ.គម របស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២
- លិខិតប្រគល់ត្រាលេខ ០៣៨.២០០២ កគត ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០២ របស់ការិយាល័យគ្រប់គ្រងត្រានៃក្រសួងមហាផ្ទៃ ។

ក្រសួងសាធារណការ និង ដឹកជញ្ជូន សូមជំរាបជូនដំណឹងដល់គ្រប់ស្ថាប័ន ក្រសួង ខេត្ត-ក្រុង និង មន្ទីរ អោយបានជ្រាបថា រាជរដ្ឋាភិបាលបានសំរេច :

១. អនុញ្ញាតិអោយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និង ដឹកជញ្ជូន មានត្រាមូលសំរាប់ប្រើប្រាស់ក្នុងការងារជំនាញពាក់ព័ន្ធ នឹងវិស័យដឹកជញ្ជូនរបស់ខ្លួន ( ដូចមានជូនភ្ជាប់មកជាមួយនូវគំរូត្រា) ។

២. ប្រគល់សិទ្ធជូនអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ដើម្បីចុះហត្ថលេខាសំរេចលើឯកសារមធ្យោបាយយានយន្ត-ជលយានគ្រប់ប្រភេទ មានជាអាទិ:

- ប័ណ្ណសំគាល់យានយន្ត-ជលយាន
- លិខិតអាជីវកម្មដឹកជញ្ជូន
- ប័ណ្ណបើកបរ
- វិញ្ញាបនប័ត្រ
- សៀវភៅវិជ្ជាជីវៈនាវិក
- លិខិតអនុញ្ញាតិនាវាចូលកំពង់ផែ (Entry Permit) និង
- ឯកសារពាក់ព័ន្ធនឹងកិច្ចការដឹកជញ្ជូនដទៃទៀត សំរាប់ដោះស្រាយការងារប្រចាំថ្ងៃ។

អាស្រ័យហេតុនេះ សូមគ្រប់ស្ថាប័ន ក្រសួង ខេត្ត-ក្រុង និង មន្ទីរ មេត្តាជ្រាប និង ទទួលស្គាល់ជាផ្លូវការ ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះតទៅ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សំ_ស៊ុខ

**ចំលងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ខេត្ត-ក្រុង
  " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទ
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

## គំរូត្រាមូលរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន

(ឧបសម្ព័ន្ធលិខិតលេខ ០១២ សក.សជណ ចុះថ្ងៃ ទី ១១ ខែ មិនា ឆ្នាំ ២០០២ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន) ។

**គំរូត្រាមូល**

